**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ |
| ភាគីដាក់ឯកសារ: | សហមេធាវីរបស់លោក អៀង សារី |
| ដាក់ជូន: | អង្គជំនុំជម្រះសាលាដំបូង |
| ភាសាដើម: | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ: | ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១២ |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Jun-2012, 13:52
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើសុំលើកទីពីររបស់លោក អៀង សារី អនុលោមតាមវិធាន ៨៧(៤) ទាក់ទងនឹងឯកសារដែលប្រើប្រាស់ក្នុងអំឡុងពេលសាកសួរដេញដោលអ្នកជំនាញ DAVID CHANDLER**

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម យូរ ឧត្តរ៉ា | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្តីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | **ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់** |
| | ចៅក្រមបំរុង ធូ មណី | |
| | ចៅក្រមបំរុង Claudia FENZ | |

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) អនុលោមទៅតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង អវតក តទៅនេះស្នើសុំដាក់ឯកសារបន្ថែមចំនួន[1] នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងស្នើសុំឱកាសប្រើប្រាស់ឯកសារនេះក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ David Chandler ។ សំណើសុំនេះត្រូវធ្វើឡើងជាចាំបាច់ ដោយសារតែមានឯកសារដែលពាក់ព័ន្ធ និងដែលអាចបង្ហាញតម្រុយ ដែលមេធាវីការពារក្តីពិចារណាថា ជាការចាំបាច់ដែលត្រូវដាក់ឯកសារទាំងនេះនៅចំពោះមុខសាស្ត្រាចារ្យ David Chandler ហើយឯកសារទាំងនះមិនទាន់បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬដាក់លេខជា E3 ។

## I ច្បាប់

១. វិធាន ៨៧(១) ចែងថា “លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក។

២. វិធាន ៨៧(៣) ចែងនៅផ្នែកពាក់ព័ន្ធថា:

អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា ៖

ក-មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា

ខ-មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ

គ-មិនសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង

ឃ-ច្បាប់មិនអនុញ្ញាត ឬ

ង-មានចេតនាពន្យាកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។

៣. វិធាន ៧៨(៤) ចែងថា:

ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬ តាមការស្នើសុំរបស់ភាគីអង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវ

[1] សូមមើលសំណើសុំរបស់លោក អៀង សារី អនុលោមតាមវិធាន ៨៧(៤) ទាក់ទងនឹងឯកសារ ដែលអាចប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ David Chandler ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ E172/24/3 ។

ភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឲ្យបានច្បាស់លាស់ ។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន៨៧(៣) ខាងលើ ។ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ។

## II. អំណះអំណាង

៤. មេធាវីការពារក្តីស្វែងរកដាក់ឯកសារបន្ថែមដូចខាងក្រោម[2]នៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីអាចប្រើប្រាស់ជាមួយសាស្ត្រាចារ្យ David Chandler ។ អង្គជំនុំជម្រះ និងភាគីទាំងអស់អាចរកឯកសារទាំងអស់នេះនៅក្នុងឃ្លាំងផ្ទុកឯកសាររួម (Shared Materials Drive) ឬអាចមានស្រាប់ហើយនៅក្នុងសំណុំរឿង០០២:

ក. Chandler, ប្រវត្តិសាស្ត្រកម្ពុជា និពន្ធលើកទី៤ (A History of Cambodia) (មានតែ ERNs សម្រិតសម្រាំងប៉ុណ្ណោះ)[3] ។

ខ. Chandler, បងធំទី១: ជីវប្រវត្តិនយោបាយរបស់ ប៉ុល ពត (A Political Biography of Pol Pot) និពន្ធលើកទី១ (មានតែ ERNs សម្រិតសម្រាំងប៉ុណ្ណោះ)[4]។

គ. D288/4.59.1 សក្ខីកម្មរបស់សាស្ត្រាចារ្យ David Chandler នៅក្នុងករណី ០០១ ។

ឃ. D108/50/1.74, Nayan Chanda, បងប្អូនសត្រូវ (Brother Enemy) (មានតែ ERNs សម្រិតសម្រាំងប៉ុណ្ណោះ)[5]។

ង. D222/1.16, Vann Nath, A Cambodian Prison Portrait (មានតែ ERNs សម្រិតសម្រាំងប៉ុណ្ណោះ)[6]។

៥. ឯកសារពីរដំបូងនៅផ្នែក(ក-ខ) គឺជាឯកសារថ្មីដែលមិនអាចរកបាននៅក្នុងសំណុំរឿងទេ ប៉ុន្តែអង្គ

---

[2] ដូចខាងលើ ។

[3] ERN ជាភាសាអង់គ្លេស 00817575-00817577, 00817586, 00817701, 00817712, 00817724, 00817751

[4] ERN ជាភាសាអង់គ្លេស 00818401-00818404, 00818412, 00818489, 00818494, 00818524

[5] ERN ជាភាសាអង់គ្លេស 00192169, 00192173, 00192245-00192246, 00192605.

[6] ERN ជាភាសាអង់គ្លេស 00396758-00396761, 00396807-00396808

ជំនុំជម្រះ និងភាគីទាំងអស់អាចរកវាបាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម។ ឯកសារពីរនេះជាសំណៅ (version) នៃសៀវភៅពីរផ្សេងគ្នាដែលនិពន្ធដោយសាស្ត្រាចារ្យ David Chandler ដែលមានរួចជាស្រេចនៅក្នុងសំណុំរឿង ។ ទំព័រសម្រិតសម្រាំងពីសំណៅនៃសៀវភៅទាំងពីរនេះ ត្រូវបានស្នើឡើងដោយមេធាវីការពារក្តីថាពាក់ព័ន្ធ ដើម្បីបង្ហាញថាព័ត៌មាននិង/ឬយល់ឃើញរបស់សាស្ត្រាចារ្យ David Chandler បានផ្លាស់ប្តូររវាងសំណៅទាំងពីរ(version) ឬដើម្បីបង្ហាញពីសង្គតភាពរបស់ព័ត៌មាន និង/ឬទស្សនៈ។ សម្រាប់មូលហេតុនេះ ឯកសារពីរនេះមិនច្រំដែលនៃឯកសារដទៃទៀតនៅក្នុងសំណុំរឿងឡើយ ហើយក៏មិនមានចេតនាពន្យារពេលដំណើរការនីតិវិធីដែរ។

៦. ឯកសារទាំងពីរនេះត្រូវតែបានទទួលយក ដោយអនុលោមទៅតាមវិធាន ៨៧(៤)។ បើទោះបីជាឯកសារពីរនេះមាននៅមុនការចាប់ផ្តើមការជំនុំជម្រះ ក៏ភាពពាក់ព័ន្ធរបស់វានៅពេលនោះមិនបានដឹងដល់មេធាវីការពារក្តីដែរ ។ ភាគីនឹងមិនត្រូវបានបាត់បង់សិទ្ធិដោយការប្រើប្រាស់ឯកសារពីរនេះដោយមេធាវីការពារក្តីនៅសវនាការនោះទេ ដោយសារពួកគេនៅមានពេលវេលាគ្រប់គ្រាន់នៅមុនការផ្តល់សក្ខីកម្មរបស់សាស្ត្រាចារ្យ David Chandler ដើម្បីពិនិត្យ និងវាយតម្លៃឯកសារនេះ ។

៧. ឯកសារបីចុងក្រោយខាងលើ (គ-ង) អាចរកបាននៅក្នុងសំណុំរឿង និងត្រូវបានស្នើឡើងដោយបញ្ជីឯកសាររបស់ភាគីដទៃទៀត[7]។ ឯកសារនេះមិនត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសាររបស់មេធាវីការពារក្តីនោះទេ ពីព្រោះមេធាវីការពារក្តីមិនបានដឹងពីសារៈសំខាន់របស់វានៅពេលរៀបចំបញ្ជីឯកសាររបស់ខ្លួន ។ ជាញឹកញាប់ការដឹងពីសារសំខាន់របស់ឯកសារបានកើតឡើងនៅពេលពិនិត្យមើលឯកសារជាក់លាក់នៅក្នុងបរិបទជាមួយឯកសារដទៃទៀត។ ដូចជាករណីឯកសារនេះជាដើម។ ភាគីនឹងមិនត្រូវបានបាត់បង់សិទ្ធិដោយការប្រើប្រាស់ឯកសារពីរនេះដោយមេធាវីការពារក្តីនៅសវនាការឡើយ ដោយសារឯកសារទាំងនេះមាននៅក្នុងសំណុំរឿង ហើយហេតុដូច្នេះវាអាចរកបានដោយភាគីទាំងអស់ ។

**អាស្រ័យដូចបានបញ្ជាក់ក្នុងមូលហេតុខាងលើ** មេធាវីការពារក្តីស្នើសុំដាក់ឯកសារដែលស្នើពីខាងលើនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងស្នើសុំឱកាសប្រើប្រាស់ឯកសារនេះក្នុងអំឡុងពេលសួរដេញដោលសាស្ត្រាចារ្យ David Chandler ។

---

[7] សូមមើលឧទាហរណ៍បញ្ជីឯកសាររបស់ កសព E9/31.11; E9/31.19 ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១២

________________ ________________

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**